**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិ**

**រៀបចំបុណ្យជាតិ-អន្តរជាតិ**

លេខ:......០១/........គជបអ
/២០២៦

# ផែនការណែនាំ

## ស្តីពី

## ការរៀបចំពិធីបុណ្យមាឃបូជា

បុណ្យ **មាឃបូជា** គឺជាបុណ្យមួយនៃបណ្តាបុណ្យធំៗទាំងឡាយ ក្នុងព្រះពុទ្ធសាសនា ដែលប្រទេសកាន់ព្រះពុទ្ធសាសនាលើសកលលោក តែងតែប្រារព្ធធ្វើពុំដែលខាន។

ពិធីបុណ្យនេះ ប្រារព្ធធ្វើឡើងដើម្បីរម្លឹកដល់អភិលក្ខិតសម័យទាំងពីរ នៃសាសនាព្រះសម្មាសម្ពុទ្ធបរមគ្រូ ដែលកើតឡើងនៅថ្ងៃពេញបូណ៌មី ខែមាឃដូចគ្នា គឺ ថ្ងៃប្រជុំចតុរង្គសន្និបាត និងថ្ងៃដែលព្រះអង្គទ្រង់ប្រកាសដាក់ព្រះជន្មាយុសង្ខារ។

ជារៀងរាល់ឆ្នាំ ពុទ្ធសាសនិកជនខ្មែរយើង តែងតែប្រារព្ធធ្វើពិធីបុណ្យមាឃបូជា នៅគ្រប់វត្តអារាមទូទាំងប្រទេស ដោយចាត់ទុកថា ជាការបំពេញកុសលដ៏ថ្លៃថ្លាបំផុត។

រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ក៏បានចាត់ចែងរៀបចំពិធីបុណ្យនេះ នៅបរិវេណ **ព្រះមហាសក្យមុនីចេតិយ ភ្នំព្រះរាជទ្រព្យ (ឧត្តុង្គ)** ស្រុកពញាឮ ខេត្តកណ្តាល ដោយមានថ្នាក់ដឹកនាំជាន់ខ្ពស់ ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល មន្ត្រីរាជការ អ្នកមុខអ្នកការ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត សិស្ស សីលវន្ត សីលវតី និងពុទ្ធបរិស័ទចូលរួមបំពេញកុសល ស្របតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលបានចែងថា **ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ។**

ឆ្នាំនេះ ពិធីបុណ្យ **មាឃបូជា** នឹងត្រូវប្រព្រឹត្តទៅរយៈពេល ២ថ្ងៃ គឺថ្ងៃចន្ទ ១៥កើត និងថ្ងៃអង្គារ ១រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២ និងថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៦។

ដើម្បីញ៉ាំងពិធីបុណ្យនេះ ឱ្យប្រព្រឹត្តទៅយ៉ាងមហោឡារិក ស្របតាមប្រពៃណីព្រះពុទ្ធសាសនា គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ សូមធ្វើការណែនាំដូចខាងក្រោម ៖

★ក្រសួងព្រះបរមរាជវាំង

រៀបចំព្រះរាជពិធីបុណ្យមាឃបូជា នៅក្នុងព្រះបរមរាជវាំង តាមព្រះរាជប្បវេណី និងតាមការសព្វព្រះរាជហឫទ័យរបស់ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។

★គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

សហការជាមួយក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្តពាក់ព័ន្ធ ចាត់តាំងរៀបចំពិធីបុណ្យមាឃបូជា ជាផ្លូវការនៅបរិវេណ **ព្រះមហាសក្យមុនីចេតិយ ភ្នំព្រះរាជទ្រព្យ (ឧត្តុង្គ)** ស្រុកពញាឮ ខេត្តកណ្តាល ក្នុងរយៈពេលមួយថ្ងៃ គឺនៅថ្ងៃពេញបូណ៌មី ខែមាឃ ដោយពេលព្រឹកមានកម្មវិធី



វិថីឧកញ៉ា ឈុន កែងតិរវិថីព្រះស៊ីសុវត្ថិ ទល់មុខសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ E-mail: nconif@gmail.com Phone: 012 912 265 / 097 97 69 111

ហែប្រទក្សិណ**ព្រះមហាសក្យមុនីចេតិយ** និងថ្វាយគ្រឿងសក្ការបូជា នមស្ការព្រះរតនត្រ័យ សមាទានសីល វេរភត្ត ឧទ្ទិសកុសល និងយាង និមន្តព្រះសង្ឃបិណ្ឌបាត នៅឧបដ្ឋានសាលាខាងក្រោម ដែលស្ថិតខាងកើត **ព្រះមហាសក្យមុនីចេតិយ**។ នៅពេលល្ងាច និងថ្ងៃបន្ទាប់ជាឱកាសប្រគេនព្រះសង្ឃ ជូនពុទ្ធបរិស័ទថ្វាយគ្រឿងសក្ការបូជា នមស្ការព្រះរតនត្រ័យ ប្រកាសមាឃបូជា សូត្រនមក្ការគាថា សម្តែងធម៌ទេសនា បំពេញកុសល តាមសទ្ធាជ្រះថ្លារបស់ពុទ្ធបរិស័ទ ស្របតាមប្រពៃណីព្រះពុទ្ធសាសនា។

ចាត់ចែងគ្រឿងសក្ការបូជា និងទេយ្យទាន សម្រាប់ថ្វាយ ប្រគេនសម្តេចព្រះសង្ឃ ព្រះសង្ឃយាង និមន្តបិណ្ឌបាតផ្លូវការ តុបតែងលម្អទីតាំងប្រារព្ធពិធីបុណ្យនៅឧបដ្ឋានសាលា ដោយមានដំឡើងផ្ទាំងប៉ាណូធំៗស្តីពីព្រះពុទ្ធទ្រង់ប្រសូត ព្រះពុទ្ធទ្រង់ត្រាស់ដឹង ព្រះពុទ្ធទ្រង់បរិនិព្វាន និងលើកទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ ទង់រំយោល ទង់ក្ដែប ព្រមទាំងបដាពាក្យស្លោក។

អំពាវនាវសប្បុរសជន ពុទ្ធបរិស័ទ ប្រជាពលរដ្ឋ អញ្ជើញចូលរួមបំពេញកុសល តាមសទ្ធាជ្រះថ្លា ដើម្បីជាគុណប្រយោជន៍ដល់ការថែរក្សានូវអត្តសញ្ញាណជាតិ ប្រពៃណីព្រះពុទ្ធសាសនា និងអនុមោទនា យកផលានិសង្ស រៀងៗខ្លួន។

★<u>រដ្ឋបាលខេត្តកណ្តាល</u>

សហការជាមួយ គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ រៀបចំពិធីបុណ្យ ចាត់ចែងយាង និមន្តព្រះសង្ឃ អញ្ជើញមន្ត្រីរាជការ សីលវន្ត សីលវតី ពុទ្ធបរិស័ទ ប្រជាពលរដ្ឋ ព្រមទាំងសិស្សានុសិស្សចូលរួម និងចាត់កម្លាំងសម្អាតទីតាំងប្រារព្ធពិធីបុណ្យ តុបតែងលម្អតាមដងផ្លូវ និងកម្លាំងការពារក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គម ចរាចរណ៍ មុន-ក្រោយ និងក្នុងពេលប្រារព្ធពិធីបុណ្យ ដោយធានាឱ្យមានសុវត្ថិភាពល្អប្រសើរ។

ណែនាំប្រជាពលរដ្ឋដែលរស់នៅតាមដងផ្លូវជាតិលេខ៥ ផ្លូវចូលទៅកាន់ភ្នំព្រះរាជទ្រព្យ និងផ្លូវជុំវិញភ្នំព្រះរាជទ្រព្យ ឱ្យធ្វើអនាម័យ តុបតែងលម្អដោយផ្កាភ្ញី បំភ្លឺភ្លើង លើកទង់ជាតិ ទង់សាសនា ឱ្យបានគ្រប់គេហដ្ឋាន។

ដំឡើងផ្ទាំងប៉ាណូធំៗស្តីពីព្រះពុទ្ធទ្រង់ប្រសូត ព្រះពុទ្ធទ្រង់ត្រាស់ដឹង និងព្រះពុទ្ធទ្រង់បរិនិព្វាន។

★<u>គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្តពាក់ព័ន្ធ</u>

ចាត់ថ្នាក់ដឹកនាំ មន្ត្រីរាជការ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត សិស្ស ពុទ្ធបរិស័ទ និងប្រជាពលរដ្ឋចូលរួមក្នុងពិធីបុណ្យមាឃបូជា នៅឧបដ្ឋានសាលាខាងក្រោម ស្ថិតខាងកើត **ព្រះមហាសក្យមុនីចេតិយ ភ្នំព្រះរាជទ្រព្យ (ឧត្តុង្គ)** និងណែនាំឱ្យតុបតែងលម្អដោយលើកទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ បដាពាក្យស្លោក នៅតាមក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត តាមអគារសាធារណៈ រោងចក្រ សហគ្រាស វត្តអារាម និងគ្រប់គេហដ្ឋានប្រជាពលរដ្ឋ ដើម្បីអបអរសាទរពិធីបុណ្យប្រពៃណីព្រះពុទ្ធសាសនា។

★<u>ក្រសួងធម្មការ និងសាសនា</u>

ណែនាំគ្រប់មន្ទីរធម្មការ និងសាសនា រាជធានី ខេត្ត ឱ្យរៀបចំពិធីបុណ្យមាឃបូជា តាមវត្តនីមួយៗ ឱ្យបានសមស្របតាមទំនៀមទម្លាប់ ប្រពៃណីជាតិ និងជ្រើសតាំងវត្តណាមួយប្រារព្ធពិធីបុណ្យមាឃបូជា ជាផ្លូវការ។

★<u>ក្រសួងព័ត៌មាន</u>

ចាត់បណ្តាញ វិទ្យុ ទូរទស្សន៍ជាតិ និងឯកជន ឱ្យចុះយកព័ត៌មាន ធ្វើសកម្មភាពថតរូប ថតទូរទស្សន៍ក្នុងពេលប្រារព្ធពិធីបុណ្យ និងណែនាំឱ្យមានការផ្សព្វផ្សាយធម្មទេសនា អំពីប្រវត្តិនៃពិធីបុណ្យមាឃបូជានេះឱ្យបានទូលំទូលាយស័ក្តិសម ជាទិវាបុណ្យប្រពៃណីព្រះពុទ្ធសាសនាដ៏រុងរឿង។

**✶ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

ចាត់កម្លាំងសិស្សសូត្របទនគររាជ គោរពទង់ជាតិ និងបទសរភេញ្ញ គោរពទង់ព្រះពុទ្ធសាសនា ព្រមទាំងនារីសម្រាប់ស្មូតក្នុងពេលរាប់បាត្រ។

**✶រដ្ឋបាលខេត្តនីមួយៗ**

ត្រូវរៀបចំប្រារព្ធពិធីបុណ្យមាឃបូជា ជាផ្លូវការនៅទីវត្តណាមួយក្នុងមូលដ្ឋាន ដែលនឹងអាចដំណើរការបានដោយនិមន្តមន្ត្រីសង្ឃ អញ្ជើញថ្នាក់ដឹកនាំខេត្ត មន្ត្រីរាជការតាមមន្ទីរ អង្គភាព ក្រុង ស្រុក ឃុំ សង្កាត់ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត សិស្ស សីលវន្ត សីលវតី និងពុទ្ធបរិស័ទចូលរួម និងណែនាំគ្រប់មន្ទីរ អង្គភាព សាលារៀន អគារសាធារណៈ រោងចក្រ សហគ្រាស វត្តអារាម ឱ្យតុបតែងលម្អដោយលើកទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ បដាពាក្យស្លោក និងបំផុសប្រជាពលរដ្ឋឱ្យលើកទង់ជាតិ ទង់សាសនា គ្រប់គេហដ្ឋាន។

**✶ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

ជួយបង្កលក្ខណៈងាយស្រួលដោះស្រាយសម្ភារថវិកា សម្រាប់បម្រើការរៀបចំពិធីបុណ្យមាឃបូជា ឱ្យបានសមស្របតាមសំណូមពរ។

**✶ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ**

ណែនាំដល់អង្គភាពក្រោមឱវាទ សហការការពាររក្សាសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់សង្គម ចរាចរណ៍ ធានាសុវត្ថិភាពក្នុងពិធីបុណ្យគ្រប់ទីកន្លែង ទាំងនៅ **ព្រះមហាសក្យមុនីចេតិយ ភ្នំព្រះរាជទ្រព្យ** (**ឧត្តុង្គ**) ស្រុកពញាឮ ខេត្តកណ្តាល និងនៅគ្រប់ខេត្ត។

គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ សង្ឃឹមថាថ្នាក់ដឹកនាំគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត នឹងយកចិត្តទុកដាក់អនុវត្តនូវផែនការណែនាំនេះ ឱ្យបានសម្រេចលទ្ធផលល្អប្រសើរ។

ថ្ងៃអង្គារ ៣រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែមករា ឆ្នាំ២០២៦
**ជ.គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ**
**ប្រធាន**

**សម្តេចមហាមន្ត្រី គុយ សុផល**

**ចម្លងជូន-ជូន៖**
- សម្តេចព្រះមហាសង្ឃរាជ ទាំងពីរគណៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រីប្រចាំការ
  "ដើម្បីជូនជ្រាប"
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត
  "ដើម្បីសហការអនុវត្ត"
- ឯកសារ កាលប្បវត្តិ

# ពាក្យស្លោក
## សម្រាប់ប្រើក្នុងពិធីបុណ្យមាឃបូជា
## ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

១- អបអរសាទរ ពិធីបុណ្យមាឃបូជា ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

២- សូមថ្វាយព្រះពរ **ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា សូមមានព្រះរាជសុខភាពល្អ បរិបូរណ៍ និងព្រះជន្មាយុយឺនយូរ

៣- សូមថ្វាយព្រះពរ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** សូមមានព្រះរាជសុខភាពល្អ បរិបូរណ៍ និងព្រះជន្មាយុយឺនយូរ

៤- សូមថ្វាយព្រះរាជកុសល ព្រះវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ"** សូមបានយាងទៅសោយព្រះបរមសុខ ក្នុងសុគតិភព

៥- ជយោ! ព្រះរាជាណាចក្រកម្ពុជា

៦- ជាតិ សាសនា ព្រះមហាក្សត្រ

៧- ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ

៨- **នត្ថិ សន្តិ បរំ សុខំ** គ្មានសុខអ្វីស្មើនឹងសេចក្តីស្ងប់

៩- **សុខោ បុញ្ញស្ស ឧច្ចយោ** ការសន្សំបុណ្យនាំមកនូវសេចក្តីសុខ

១០- អហិង្សា ជាគោលការណ៍រួមនៃព្រះពុទ្ធសាសនា

១១- សុភមង្គល និងការអភិវឌ្ឍ ជាសំណូមពរដ៏ពិសិដ្ឋរបស់ព្រះពុទ្ធសាសនា

១២- សូមព្រះធម៌របស់ព្រះពុទ្ធបរមគ្រូជ្រួតជ្រាបដល់គ្រប់មនុស្សជាតិទូទៅ

១៣- ជយោ! សន្តិភាព ដោយនយោបាយ ឈ្នះ ឈ្នះ

១៤- ជយោ! នយោបាយ ឈ្នះ ឈ្នះ នាំមកនូវសន្តិភាព

១៥- ជយោ! សន្តិភាព ប្រជាធិបតេយ្យ និងអភិវឌ្ឍន៍

១៦- ជយោ! សន្តិភាព និងការអភិវឌ្ឍ

១៧- ជយោ! សន្តិភាព និងការបង្រួបបង្រួមជាតិ

១៨- មានសន្តិភាពទើបមានការអភិវឌ្ឍប្រទេសជាតិ